# 3. របៀបទទួលបានការថែទាំ

## ការថែទាំសម្រាប់រឿងឯកជន

### សេវាការយល់ព្រមពីអនីតិជន

ប្រសិនបើអ្នកមានអាយុក្រោម 18 ឆ្នាំ អ្នកមិនចាំបាច់ត្រូវការការអនុញ្ញាតពីឪពុកម្តាយ ឬអាណាព្យាបាល ដើម្បីទទួលបានសេវាថែទាំសុខភាពមួយចំនួននោះទេ ហើយអ្នកអាចទទួលវាដោយសម្ងាត់បាន ដែលមានន័យថា ឪពុកម្តាយ ឬអាណាព្យាបាលរបស់អ្នកនឹងមិនទទួលបានការជូនដំណឹង ឬទាក់ទងឡើយ ប្រសិនបើអ្នកទទួលបានសេវាទាំងនេះ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នក។ សេវាទាំងនេះហៅថា សេវាការយល់ព្រមពីអនីតិជន។

អ្នកអាចទទួលបានសេវាខាងក្រោម នៅក្រោម**អាយុ 12 ឆ្នាំ**៖

- សេវាឆ្លើយតបនឹងការរំលោភបំពានផ្លូវភេទ
- ការមានគភ៌ និងសេវាទាក់ទងនឹងការមានគភ៌
- សេវារៀបចំផែនការគ្រួសារ ដូចជាសេវាពន្យារកំណើត (ឧទាហរណ៍ ថ្នាំពន្យារកំណើត)

បន្ថែមលើសេវាដែលបានរាយខាងលើ អ្នកក៏អាចទទួលបានសេវាខាងក្រោមនៅ**អាយុ 12 ឆ្នាំឡើងទៅ** ផងដែរ៖

- ការព្យាបាល ឬការប្រឹក្សាជំងឺផ្លូវចិត្តសម្រាប់អ្នកជំងឺឥតដេកពេទ្យ។ នេះនឹងអាស្រ័យលើភាពចាស់ទុំ និងសមត្ថភាពរបស់អ្នកក្នុងការសម្រេចចិត្តលើការថែទាំសុខភាពរបស់អ្នក ដូចដែលបានវាយតម្លៃដោយអ្នកជំនាញ
- ការឆ្លងមេរោគ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺឆ្លង រួមទាំងមេរោគអេដស៍/ជំងឺអេដស៍
- ការបង្ការជំងឺកាមរោគ (STI) ការធ្វើតេស្ត ការធ្វើរោគវិនិច្ឆយ និងការព្យាបាលសម្រាប់ជំងឺ STI ដូចជាជំងឺស្វាយ ជំងឺប្រមេះទឹកបាយ ជំងឺប្រមេះទឹកថ្លា និងជំងឺពងបែកមាត់
- សេវាឆ្លើយតបនឹងអំពើហិង្សាលើដៃគូស្និទ្ធស្នាល
- ការព្យាបាលជំងឺប្រើប្រាស់សារធាតុញៀន (SUD) សម្រាប់ការប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹងហួសហេតុ រួមទាំងសេវាពិនិត្យរក រៀបចំការវាយតម្លៃ ការព្យាបាល និងការបញ្ជូនបន្ត

អ្នកអាចទទួលបានសេវាការយល់ព្រមពីអនីតិជនពីអ្នកផ្តល់សេវា Medi-Cal ឬគ្លីនិកណាមួយ។ អ្នកផ្តល់សេវាមិនចាំបាច់នៅក្នុងបណ្តាញ Blue Shield Promise ទេ។ អ្នកមិនចាំបាច់ត្រូវការការបញ្ជូនបន្តពី PCP របស់អ្នក ឬការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន) ទេ។

ប្រសិនបើអ្នកប្រើអ្នកផ្តល់សេវានៅក្រៅបណ្តាញសម្រាប់សេវាដែល **មិន** ទាក់ទងនឹងសេវាសម្រាប់អនីតិជនដែលត្រូវយល់ព្រមដោយខ្លួនឯង នោះសេវានោះអាចនឹងមិនត្រូវបានរ៉ាប់រងឡើយ។

ដើម្បីស្វែងរកអ្នកផ្តល់សេវា Medi-Cal នៅខាងក្រៅបណ្តាញរបស់ Blue Shield Promise Medi-Cal សម្រាប់សេវាការយល់ព្រមពីអនីតិជន ឬដើម្បីស្នើសុំជំនួយដឹកជញ្ជូនដើម្បីទៅជួបអ្នកផ្តល់សេវា សូមហៅទូរសព្ទទៅកាន់ផ្នែកសេវាបម្រើសមាជិករបស់ Blue Shield Promise តាមរយៈលេខ 1-800-605-2556 (TTY 711)។

---

សម្រាប់ព័ត៌មានបន្ថែមអំពីសេវាបង្ការកុំឱ្យមានកូន សូមអានផ្នែក “សេវាបង្ការ និងសុខុមាលភាព និងការគ្រប់គ្រងជំងឺរ៉ុាំរ៉ៃ” នៅក្នុង ជំពូកទី 4 នៃសៀវភៅណែនាំនេះ។

Blue Shield Promise មិនរ៉ាប់រងល រីសេវាដែលអនីតិជនអាចយល់ព្រម ដោយខ្លួនឯង ដែលជាសេវាសុខភាពផ្លូវចិត្តជំនាញ (SMHS) ឬសេវា SUD ភាគច្រើននោះទេ។ ខោនធីដែលអ្នករស់នៅធានារ៉ាប់រងលើសេវាទាំងនេះ។ ដើម្បីស្វែងយល់បន្ថែម រួមទាំងរបៀបចូលប្រើសេវាទាំងនេះ សូមអាន ផ្នែក “សេវាសុខភាពផ្លូវចិត្តជំនាញ (SMHS)” និង “សេវាព្យាបាលបញ្ហាប្រើប្រាស់សារធាតុញៀន (SUD)” នៅក្នុងជំពូកទី 4 នៃសៀវភៅណែនាំនេះ។ ដើម្បីស្វែងយល់បន្ថែម សូមហៅទូរសព្ទទៅលេខ 1-800-605-2556 (TTY 711)។

សម្រាប់បញ្ជីលេខទូរសព្ទដែលឥតគិតថ្លៃរបស់ខោនធីទាំងអស់សម្រាប់ SMHS សូមចូលទៅកាន់៖ http://www.dhcs.ca.gov/individuals/Pages/MHPContactList.aspx

សម្រាប់បញ្ជីលេខទូរសព្ទដែលឥតគិតថ្លៃរបស់ខោនធីទាំងអស់សម្រាប់សេវាព្យាបាល SUD សូមចូលទៅកាន់៖ https://www.dhcs.ca.gov/individuals/Pages/SUD_County_Access_Lines.aspx។

អនីតិជនអាចនិយាយទៅកាន់អ្នកតំណាងម្នាក់ដោយសម្ងាត់អំពីបញ្ហាសុខភាពរបស់គេ ដោយហៅទូរសព្ទទៅបណ្ដាញទូរសព្ទគិលានុបដ្ឋាយិកា 24/7 តាមរយៈលេខ 1-800-609-4166 (TTY 711)។ អ្នកអាចស្នើសុំព័ត៌មានឯកជនស្ដីពីសេវាវេជ្ជសាស្ត្ររបស់អ្នកក្នុងទម្រង់ ឬប្រភេទណាមួយ ប្រសិនបើមាន។ អ្នកអាចឱ្យគេផ្ញើវាទៅអ្នកនៅទីតាំងមួយផ្សេងទៀត។ ដើម្បីស្វែងយល់បន្ថែមអំពីរបៀបស្នើសុំការទំនាក់ទំនងសម្ងាត់ ដែលទាក់ទងនឹងសេវារសើប សូមអាន “សេចក្ដីជូនដំណឹងស្ដីពីការអនុវត្តការសម្ងាត់” នៅក្នុងជំពូកទី 7 នៃសៀវភៅណែនាំនេះ។